## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ០២៥៨ ព.ណ.កសប

ថ្ងៃ សុក្រ ៨កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០២១

## ជម្រាបមក
## លោក/លោកស្រីប្រធាន ក្រុមហ៊ុន ពន្លឺ អលង្ការ

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលបីចែងម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ពន្លឺ អលង្ការ**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ពន្លឺ អលង្ការ** ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២០
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ២៧៤៦ ព.ណ កសប ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១៩
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Thai Fermentation Industry Co., Ltd. ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៧៧៥១/០៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រា ទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលបីចែងពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ពន្លឺ អលង្ការ** ដែលទទួលបានពីក្រុមហ៊ុន Thai Fermentation Industry Co., Ltd. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតបន្តសុពលភាពកត់ត្រា និងតម្កល់សិទ្ធផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Thai Fermentation Industry Co., Ltd. ដែលជាម្ចាស់ម៉ាក។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រាជ្ញា**

*<u>ចម្លងជូន:</u>*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម

# កំណត់បង្ហាញ
# ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខ

- **កម្មវត្ថុ៖** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលម៉ាក
- **អ្នកស្នើសុំ៖ ក្រុមហ៊ុន ពន្លឺ អលង្ការ**
- **យោង៖** គោលការណ៍ឯកភាព**ឯកឧត្តមរដ្ឋមន្ត្រី** ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២១

ដោយមានចំណារឯកភាពឯកឧត្តមរដ្ឋមន្ត្រី គួរធ្វើការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើម៉ាកជូន។

**ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

01.02.21

**លុយ សុផល្លា**

| **យោបល់ឯកឧត្តមអគ្គនាយក** 01/2/21 2:40pm | **យោបល់អនុប្រធាននាយកដ្ឋាន** |
|---|---|
| 01-02-2021 | **គោរពជូន**<br>យោងមាត្រា៣ និង១១ នៃច្បាប់ម៉ាក និងឯកសារតម្រូវដែលបានដាក់មកនាងខ្ញុំ/ខ្ញុំបាទយល់ឃើញថា ក្រសួងអាចអនុញ្ញាតឲ្យធ្វើការ កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខបាន តាមការស្នើសុំ ។<br>សូមលោកប្រធាន ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច តាមការ គួរ។<br>01.02.21 |
| **យោបល់របស់ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ** | **យោបល់ប្រធាននាយកដ្ឋាន** |
| **រដ្ឋលេខាធិការ**<br>3/2/21<br>**អ៊ុក ប្រឹជា** | **យោងគោលការណ៍ឯកភាពរបស់ ឯកឧត្តមរដ្ឋមន្ត្រី៖** ……………<br>សូម ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច ដោយក្ដីអនុគ្រោះ។<br>01 FEB 2021<br>**សួន វីជ្ជា** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
នាយកដ្ឋានកម្មសិទ្ធិបញ្ញា

## កំណត់បង្ហាញ

**កម្មវត្ថុ** ៖ សំណើសុំបន្តកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការនាំចូល និងចែកចាយផលិតផលម៉ាក របស់ក្រុមហ៊ុន **ពន្លឺ អលង្ការ**។

| ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី | |
|---|---|
| ចូល | លេខ៖ 0230<br>ថ្ងៃទី៖ 28 01 21<br>ម៉ោង៖ 4:00 |

**អ្នកស្នើសុំ** ៖ ក្រុមហ៊ុន **ពន្លឺ អលង្ការ**

**ខ្លឹមសារ** ៖ ☑ មានលិខិតស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខ
☑ មានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីក្រុមហ៊ុនបរទេស
☑ មានឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុនក្នុងស្រុក
☑ មានឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកនេះ។

ដូច្នេះការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខអាចធ្វើឡើងបាន ដោយសារលិខិតប្រគល់សិទ្ធិនៅមានសុពលភាព ដូចមានចែងក្នុងប្រការ ១១(២)(២)(៥) និង(៦) នៃប្រកាស។

☐ ២ឆ្នាំ
☑ តិចជាង ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គនាយក ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ** និង **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី 27 ខែ 1 ឆ្នាំ២០២១

**ប្រធាននាយកដ្ឋាន**

**សួន វិជ្ជា**

| យោបល់របស់ឯកឧត្តមអគ្គនាយក | យោបល់របស់ឯកឧត្តមអនុរដ្ឋលេខាធិការ |
|---|---|
| **សូមគោរពជូន**<br>**ឯកឧត្តមអនុរដ្ឋលេខាធិការ**<br>[illegible]<br>27-01-21 | **សូមគោរពជូន**<br>**ឯកឧត្តមរដ្ឋលេខាធិការ**<br>[illegible]<br>ភ្នំពេញ 27.01.21 |
| **យោបល់របស់ឯកឧត្តមរដ្ឋលេខាធិការ** | **សេចក្តីសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រី** |
| **សូមគោរពជូន**<br>**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**<br>-ឯកសារគ្រប់គ្រាន់ គួរអនុញ្ញាតឲ្យការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងករណីនេះ។<br>សូមឯ.ឧ រដ្ឋមន្ត្រីពិនិត្យ និងសម្រេច។<br>ដោយក្តីគោរព<br>**អ៊ុក-ប្រាជ្ញា** 28/1/21 | **ឯកភាពជាគោលការណ៍**<br>**ប៉ាន-សូរស័ក្តិ**<br>29. 01. 2021 |